# ការព្យាបាលនៃការឆ្លងរោគរបេងដែលមិនទាន់ចេញមុខ

លទ្ធផលពិនិត្យរោគរបស់អ្នកបង្ហាញថាអ្នកបានឆ្លងរោគរបេងដែលមិនទាន់ចេញមុខ, ឬ “LTBI” ។ នៅពេលណានរណាម្នាក់មាន LTBI នោះមេរោគរបេង (TB) នៅក្នុងខ្លួនគេគឺ “នៅសំងំ” ប៉ុន្តែមានជីវិតនៅឡើយ ។ មេរោគ TB នឹង “នៅសំងំ”ដរាបណាដែលខ្លួនរបស់អ្នកអាចវាយតទល់ជាមួយវាបាន ។ នៅពេលណាដែលអ្នកមាន LTBI នោះអ្នកមិនអាចទៅចម្លង TB ឱ្យអ្នកផ្សេងទៀតឡើយ ។

ប្រសិនបើខ្លួនរបស់អ្នកឈប់វាយតទល់ជាមួយមេរោគ TB បានតទៅទៀត, នោះវានឹង “ភ្ញាក់ឡើង” ហើយចាប់ផ្តើមរីកឡើង ។ **ការនេះវាអាចកើតឡើងចំពោះជនណាដែលមាន LTBI នៅពេលណាក៏បានដែរ** ។ នៅពេលណាដែលមេរោគចាប់លូតលាស់ ហើយរីកឡើង នោះវាត្រូវបានគេហៅថា “ជម្ងឺរបេងសកម្ម ។” មនុស្សដែលមានជម្ងឺរបេងសកម្មអាចឈឺខ្លាំង ហើយអាចចម្លងរោគរបេងទៅអ្នកដទៃបាន ។

## តើខ្ញុំអាចការពារជម្ងឺរបេងសកម្មបានដោយរបៀបណានៅ?




ថ្នាំ (Isoniazid -INH) គឺជាថ្នាំពេទ្យជាទូទៅដែលប្រើសំរាប់ព្យាបាល LTBI ។ ថ្នាំ INH ទៅសម្លាប់មេរោគ TB ដែល “កំពុងសំងំ” **នៅមុនពេល**ដែលវាមានឱកាសធ្វើឱ្យអ្នកឈឺ ។ ដោយសារតែ មេរោគ TB ខ្លាំង, អញ្ចឹងហើយវាត្រូវការពេលរាប់ខែ ដើម្បីឱ្យថ្នាំនោះទៅសម្លាប់វាបាន ។

ថ្នាំ INH មានប្រសិទ្ធិភាពបំផុតប្រសិនបើអ្នកលេបវារាល់ថ្ងៃរហូតទាល់តែគ្រូពេទ្យរបស់អ្នកប្រាប់ថាអ្នកអាចឈប់លេបវាបាន ។

អ្នកគួរតែទៅជួបពេទ្យរបស់អ្នកមួយខែម្តងនៅខៈណៈណាដែលអ្នកលេបថ្នាំ INH ដើម្បីឱ្យប្រាកដថាការព្យាបាលរបស់អ្នកគឺកំពុងទៅដោយរលូន ។

## ហេតុអ្វីបានជាខ្ញុំត្រូវលេបថ្នាំ បើខ្ញុំមិនទាំងឈឺផង?

ថ្នាំ INH សម្លាប់មេរោគ TB នៅក្នុងខ្លួនរបស់អ្នក**មុនពេល**ដែលវាមានឱកាស “ភ្ញាក់ឡើង” និងធ្វើឱ្យអ្នកឈឺ ។

## តើខ្ញុំគួរតែដឹងអំពីថ្នាំសំរាប់ព្យាបាល LTBI យ៉ាងម្តេចនៅ?

មានមនុស្សជាច្រើននាក់លេបថ្នាំ INH រាល់ថ្ងៃដោយមិនមានបញ្ហាអ្វីទេ, ប៉ុន្តែ**មានកត្តាមួយចំនួនដែលអ្នកគួរតែសង្កេតៈ**

- ក្តៅខ្លួនលើសពីបីថ្ងៃ
- ពិសារអាហារមិនឆ្ងាញ់, ស្រកទម្ងន់, ឬ មានអារម្មណ៏ថាអស់កម្លាំងដោយមិនមានមូលហេតុអ្វី
- រមួលពោះ ឬក្អួតចង្អោរៈ
- ឈឺពោះរបស់អ្នក
- ទឹកនោមឡើងពណ៌ក្រម៉ៅ (ពណ៌ទឹកតែ ឬកាហ្វេ)
- ស្បែក ឬភ្នែកឡើងលឿង
- ឡើងរមាស់ ឬកន្ទួលលើស្បែក
- ស្ពឹក ឬស្រពន់ដៃ ឬជើងរបស់អ្នក
- ក្អកលើសពីបីសប្តាហ៏ឡើងទៅ
- បែកញើសនៅពេលយប់

**ប្រសិនបើអ្នកមានបញ្ហាណាមួយនេះ, ចូរឈប់លេបថ្នាំ INH ហើយទូរស័ព្ទទៅគ្លីនិករបស់អ្នកជាបន្ទាន់– កុំរងចាំរហូតទាល់តែពេលណាត់ជួបពេទ្យលើកក្រោយ ។**

**ចំណុចសំខាន់ផ្សេងទៀតៈ**

- **ផឹកស្រា**នៅខៈណៈដែលអ្នកលេបថ្នាំ INH អាចធ្វើទុក្ខថ្លើមរបស់អ្នកបាន ។ កុំផឹកស្រាបៀរ, ស្រា, ឬគ្រឿងស្រវឹង រហូតទាល់តែអ្នកលេបថ្នាំព្យាបាល LTBI របស់អ្នកឱ្យអស់សិន ។
- ប្រាប់ពេទ្យរបស់អ្នក ប្រសិនបើអ្នកកំពុងលេប**ថ្នាំផ្សេងទៀត** ឬក៏**មានផ្ទៃពោះ** ។

យកលំនាំតាមឯកសារពីក្រសួងសុខាភិបាលនៃរដ្ឋមីនីសូតា (Minnesota Department of Health), កម្មវិធីការពារ និងត្រួតពិនិត្យជម្ងឺរបេង

### តើមានអ្វីកើតឡើង បើខ្ញុំមិនលេបថ្នាំនោះទេ?

ប្រសិនបើអ្នកមិនលេបថ្នាំ INH ឬបើអ្នកឈប់លេបថ្នាំមុនពេលកំណត់, អ្នកអាចឈឺជម្ងឺរបេងសកម្មបាន ។ នេះវាអាចកើតមានឡើងដល់**ជនទាំងឡាយណា**ដែលមាន LTBI **នៅពេលណាមួយក៏បានដែរ** ។

### តើខ្ញុំគួរតែធ្វើដូចម្តេចទៅ ប្រសិនបើខ្ញុំបានចាក់ថ្នាំ BCG រួចហើយ?

នៅប្រទេសដែលជម្ងឺ TB គឺកើតមានជាធម្មតា, មានមនុស្សជាច្រើននាក់បានចាក់ថ្នាំបង្ការដែលគេហៅថា BCG ។ BCG អាចការពារកុមារពីជម្ងឺរបេងបាន, ប៉ុន្តែវាបង្ការបានតែប៉ុន្មានឆ្នាំប៉ុណ្ណោះ ។ អ្នកដែលបានចាក់ថ្នាំ BCG អាចឆ្លងជម្ងឺរបេងសកម្មបាន! ប្រសិនបើអ្នកបានចាក់ថ្នាំ BCG រួចហើយ, អ្នកក៏អាចនៅការពារខ្លួនរបស់អ្នកបានដោយលេបថ្នាំព្យាបាល LTBI ។

### តើត្រូវធ្វើយ៉ាងដូចម្តេចទៅប្រសិនបើខ្ញុំផ្លាស់ប្តូរទីលំនៅ?

ប្រសិនបើអ្នកផ្លាស់ទីលំនៅទៅនៅរដ្ឋ ឬទីក្រុងផ្សេងទៀត, ចូរប្រាប់គ្រូពេទ្យរបស់អ្នក**នៅមុនពេលអ្នករើចេញ** ។ ពេទ្យអាចជួយអ្នកដើម្បីឱ្យប្រាកដថាអ្នកអាចទៅយកថ្នាំ TB របស់អ្នកបន្ទាប់ពីអ្នកផ្លាស់ទីលំនៅ ។

**ចូរការពារខ្លួនរបស់អ្នក, គ្រួសាររបស់អ្នក, និងមិត្តភក្ត្ររបស់អ្នកពីជម្ងឺរបេង - ចូរលេបថ្នាំ TB របស់អ្នកឱ្យអស់!**

### តើខ្ញុំអាចចាំថាត្រូវលេបថ្នាំ TB របស់ខ្ញុំយ៉ាងដូចម្តេចទៅ?

**វាជាការសំខាន់ណាស់ដែលអ្នកត្រូវលេបថ្នាំ INH រាល់ថ្ងៃ** ។ ប្រសិនបើអ្នកភ្លេចលេបថ្នាំជាច្រើនថ្ងៃ នោះថ្នាំនេះប្រហែលជាមិនមានប្រសិទ្ធិភាពទេ ។ ចូរលេបថ្នាំឱ្យអស់រហូតទាល់តែពេទ្យរបស់អ្នកប្រាប់ឱ្យឈប់លេប ។

មានយោបល់មួយចំនួនដើម្បីជួយអ្នកឱ្យចាំបាន:

- ទុកថ្នាំរបស់អ្នកនៅកន្លែងមួយដែលអ្នកនឹងឃើញវារាល់ថ្ងៃ ។
- សុំឱ្យសមាជិកគ្រួសារ ឬមិត្តភក្ត្រជួយរំលឹកអ្នក ។
- គូសចំណាំនៅលើកាលវិភាគរបស់អ្នករាល់ថ្ងៃក្រោយពេលអ្នកលេបថ្នាំរបស់អ្នករួច ។
- ប្រើប្រអប់ដាក់ថ្នាំរំលឹក ។
- លេបថ្នាំរបស់អ្នកឱ្យទៀងពេលរាល់ថ្ងៃ ។ ឧទាហរណ៍ក្រោយពេលដុះធ្មេញរួច, ពិសារអាហារពេលព្រឹក, ឬនៅមុនពេលអ្នកចូលដំណេក ។

ប្រសិនបើអ្នកខានលេបថ្នាំ, ចូរសរសេរទុកដើម្បីឱ្យអ្នកអាចប្រាប់ទៅគ្រូពេទ្យ ឬគិលានុបដ្ឋាកររបស់អ្នកនៅពេលទៅជួបពេទ្យលើកក្រោយ ។

**គ្លីនិករបស់អ្នក:**

______________________________

______________________________

______________________________

**ទូរស័ព្ទលេខ#:** ________________________

Oregon Health Authority

យកលំនាំតាមឯកសារពីក្រសួងសុខាភិបាលនៃរដ្ឋមីនីសូតា (Minnesota Department of Health), កម្មវិធីការពារ និងត្រួតពិនិត្យជម្ងឺរបេង